ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**អគ្គនាយកដ្ឋានអាស៊ាន**

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤៦

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥ តបតាមការអញ្ជើញរបស់ ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤៦ ក្រោមមូលបទ **"បរិយាបន្ន និងចីរភាព"** នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

១. <u>កិច្ចប្រជុំកំពូលអាស៊ាន លើកទី៤៦</u>

ក្នុងសម័យប្រជុំពេញអង្គ ប្រមុខដឹកនាំអាស៊ានបានពិនិត្យវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ានលើការបញ្ចប់ប្រកបដោយជោគជ័យនូវចក្ខុវិស័យសហគមន៍អាស៊ាន ឆ្នាំ២០២៥។ ប្រមុខដឹកនាំក៏បានកោតសរសើរក្រុមការងារជាន់ខ្ពស់ស្តីពីចក្ខុវិស័យសហគមន៍អាស៊ាន ឆ្នាំ២០៤៥ ក្រុមការងារជាន់ខ្ពស់សម្រាប់សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ក្រុមការងារចំពោះកិច្ចសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រសហគមន៍សង្គម-វប្បធម៌អាស៊ានក្រោយឆ្នាំ២០២៥ និងគណៈកម្មាធិការសម្របសម្រួលការតភ្ជាប់អាស៊ានដើម្បីបង្កើតចក្ខុវិស័យសហគមន៍អាស៊ាន ឆ្នាំ២០៤៥ និងផែនការយុទ្ធសាស្ត្រ ព្រមទាំងបានអនុម័តឯកសារសំខាន់ៗទាំងនេះ ទុកជាក្របខ័ណ្ឌណែនាំសម្រាប់ដឹកនាំសហគមន៍អាស៊ានក្នុងពីរទសវត្សរ៍បន្ទាប់។

ក្នុងបរិបទនៃទិដ្ឋភាពភូមិសាស្ត្រនយោបាយកាន់តែស្មុគស្មាញ និងមិនអាចប៉ាន់ស្មានទុកជាមុន ប្រមុខដឹកនាំបានអះអាងសារជាថ្មីពីសារៈសំខាន់នៃការរក្សា និងពង្រឹងមជ្ឈភាព និងឯកភាពអាស៊ានលើទំនាក់ទំនងរបស់អាស៊ានជាមួយដៃគូខាងក្រៅដែលមានស្រាប់ និងថ្មីៗ។ ប្រមុខដឹកនាំក៏បានគូសបញ្ជាក់ផងដែរពីសារៈសំខាន់នៃសមាហរណកម្មសេដ្ឋកិច្ចកាន់តែស៊ីជម្រៅ និងការបង្កើនឡើងបន្ថែមទៀតនៃលំហូរពាណិជ្ជកម្ម និងការវិនិយោគក្នុងអាស៊ាន ដោយផ្តោតលើកំណើនប្រកបដោយបរិយាបន្ន ភាពធន់ និងចីរភាព ដែលមិនទុកនរណាម្នាក់ និងកន្លែងណាមួយចោល។ ដើម្បីដោះស្រាយភាពមិនប្រាកដប្រជានៃភូមិសាស្ត្រសេដ្ឋកិច្ចដែលកំពុងកើនឡើង ប្រមុខដឹកនាំបាន


អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

បញ្ជាក់ជាថ្មីនូវការគាំទ្រប្រព័ន្ធពាណិជ្ជកម្មពហុភាគីសេរី បើកចំហ ស្មើភាព បរិយាបន្ន និងផ្អែកលើច្បាប់។

**សម្តេចធិបតី** បានបញ្ជាក់នូវការគាំទ្រយ៉ាងពេញទំហឹងរបស់កម្ពុជាចំពោះការធ្វើជាប្រធានអាស៊ានរបស់ម៉ាឡេស៊ីនៅឆ្នាំ២០២៥ ជាពិសេសបរិយាបន្ន និងចីរភាព គឺជាសសរស្តម្ភសំខាន់សម្រាប់ធានាសន្តិភាព ស្ថិរភាព និងវិបុលភាពយូរអង្វែងរបស់តំបន់។ **សម្តេចធិបតី** បានសង្កត់ធ្ងន់ថា នៅចំពោះមុខនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយកាន់តែខ្លាំង ជម្លោះប្រដាប់អាវុធអូសបន្លាយ ការថយចុះនៃកិច្ចសហប្រតិបត្តិការពហុភាគី និងការកើនឡើងនៃការគំរាមកំហែងពីបញ្ហាប្រឈមសន្តិសុខមិនប្រពៃណី អាស៊ានត្រូវតែមានការឯកភាពគ្នាលើគោលដៅ យុទ្ធសាស្ត្រលើចក្ខុវិស័យ និងភាពច្បាស់លាស់លើសកម្មភាពរួម។

**សម្តេចធិបតី** បានគូសបញ្ជាក់ពីភាពចាំបាច់នៃការធ្វើសមាហរណកម្មតំបន់ឱ្យស៊ីជម្រៅ និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូដែលមានចំណាប់អារម្មណ៍ ដើម្បីធានាថាអាស៊ាននៅតែជាតំបន់ដែលមានស្ថិរភាព និងអាចព្យាករណ៍ទុកជាមុន អំឡុងពេលពិភពលោកកាន់តែមានភាពមិនច្បាស់លាស់។ ដើម្បីបង្កើនពាណិជ្ជកម្មក្នុងអាស៊ាន **សម្តេចធិបតី** បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការសម្រួលដំណើរការនីតិវិធីឱ្យកាន់តែរលូននិងមានប្រសិទ្ធភាព ការដកចេញនូវរបាំងនានា ការបន្សុីក្របខ័ណ្ឌបទបញ្ញត្តិ និងការទទួលយកអន្តរកាលឌីជីថលនិងបរិស្ថានបៃតង ក្នុងការបង្កើតទីផ្សារតំបន់ដែលគ្មានរបាំង និងមានភាពធន់។ **សម្តេចធិបតី** បានសង្កត់ធ្ងន់បន្ថែមទៀតថា អាស៊ានត្រូវពង្រឹងការតភ្ជាប់លើគ្រប់ទិដ្ឋភាពរូបវន្ត ស្ថាប័ន និងប្រជាជននិងប្រជាជន។ នេះរួមបញ្ចូលការជំរុញគំនិតផ្តួចផ្តើមយុទ្ធសាស្ត្រគន្លឹះ ដូចជាការតភ្ជាប់បណ្តាញថាមពលអាស៊ាន ដើម្បីសម្រេចបាននូវគោលដៅរួមនៃការកាត់បន្ថយការសាយភាយឧស្ម័នកាបូន និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងការលើកកម្ពស់ទេសចរណ៍ក្នុងតំបន់ ក្នុងការធ្វើឱ្យអាស៊ានជាមជ្ឈមណ្ឌលទេសចរណ៍ដ៏រស់រវើក ចម្រុះ និងប្រកួតប្រជែង។

**សម្តេចធិបតី** បានរំលឹកឡើងវិញនូវការគាំទ្រយ៉ាងខ្លាំង និងជាប់លាប់របស់កម្ពុជាចំពោះសមាជិកភាពពេញលេញរបស់ទីម័រឡេស្តេក្នុងអាស៊ាននៅឆ្នាំនេះ និងបានគូសបញ្ជាក់ថា ការចូលជាសមាជិករបស់ទីម័រឡេស្តេនឹងមិនត្រឹមតែពង្រឹងឯកភាព និងបរិយាបន្នរបស់អាស៊ានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងសមត្ថភាពរួមរបស់អាស៊ានក្នុងការដោះស្រាយបញ្ហាប្រឈមដែលទាំងកំពុងកើតមាន និងថ្មីៗ។ សារៈសំខាន់ដូចគ្នាគឺ វានឹងអាចឱ្យទីម័រឡេស្តេចូលរួម និងទទួលបានអត្ថប្រយោជន៍ពីសមាហរណកម្មក្នុងតំបន់។ នៅពេលដែលយើងមកដល់ចំណុចដ៏សំខាន់មួយ ដែលយើងត្រូវគូសផែនទីបង្ហាញផ្លូវសម្លឹងឆ្ពោះទៅអនាគតសម្រាប់រយៈពេលពីរទសវត្សរ៍ខាងមុខ **សម្តេចធិបតី** បានរំលេចថា ចក្ខុវិស័យអាស៊ានឆ្នាំ២០៤៥ រួមទាំងផែនការយុទ្ធសាស្ត្រ នឹងដើរតួជាត្រីវិស័យនាំផ្លូវរួមសម្រាប់អាស៊ាន ឆ្ពោះទៅកាន់អនាគតប្រកបដោយភាពធន់ នវានុវត្តន៍ ថាមវន្ត និងផ្តោតលើប្រជាជនជាចម្បង។

ក្នុងអំឡុងសម័យប្រជុំចង្អៀត ប្រមុខដឹកនាំបានពិភាក្សាលើការអនុវត្តការកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច (5PC) និងការផ្លាស់ប្តូរទស្សនៈលើការវិវត្តនៃប្រយោជន៍ និងកង្វល់រួមក្នុងតំបន់ និងអន្តរជាតិ ដែលរួមមានបញ្ហាជះឥទ្ធិពលលើសេដ្ឋកិច្ចសកល និងប្រព័ន្ធពាណិជ្ជកម្មពហុភាគីផ្អែកលើច្បាប់។

២. <u>ជំនួបជាមួយប្រមុខដឹកនាំអាស៊ាន</u>

នៅក្នុងជំនួបរបស់ប្រមុខដឹកនាំអាស៊ាន ជាមួយតំណាងអន្តរសភាអាស៊ាន (AIPA) **សម្តេចធិបតី** បានគូសបញ្ជាក់ពីវិស័យគន្លឹះចំនួន៤ ដែលAIPA អាចរួមចំណែកប្រកបដោយអត្ថន័យ តាមរយៈ៖ (១) ការលើកកម្ពស់សន្តិភាព និងពហុភាគីនិយមដែលផ្តោតលើច្បាប់ និងប្រកបដោយបរិយាបន្ន (២) ការអនុម័តច្បាប់ និងត្រួតពិនិត្យការអនុវត្តការប្តេជ្ញាចិត្តនានា ដែលនឹងផ្តល់ប្រយោជន៍ដល់គ្រប់ស្រទាប់នៃសង្គម (៣) ការជំរុញកិច្ចសហការអាស៊ានលើរបៀបវារៈបៃតងតាមរយៈច្បាប់ និង(៤) ការជំរុញកិច្ចសហការជាមួយដៃគូសន្ទនាអាស៊ាន ស្ថាប័នអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីលើកកម្ពស់សមភាព ចីរភាព និងភាពធន់។

នៅក្នុងជំនួបរបស់ប្រមុខដឹកនាំអាស៊ានជាមួយតំណាងយុវជនអាស៊ាន **សម្តេចធិបតី** បានផ្តល់អនុសាសន៍ថា យុវជនគួរផ្តោតលើការពង្រឹងជំនាញ និងសមត្ថភាពចាំបាច់ ដើម្បីរក្សាភាពសមស្រប និងភាពប្រកួតប្រជែងក្នុងពិភពលោកដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនិងបានកត់សម្គាល់តួនាទីដ៏សំខាន់របស់យុវជនក្នុងការតម្រង់ទិសដៅអនាគតរបស់អាស៊ាន និងប្តេជ្ញាយ៉ាងមុតមាំក្នុងការបន្តពង្រឹងសមត្ថភាពរបស់ពួកគេ ដើម្បីធានាថាពួកគេត្រៀមលក្ខណៈរួចរាល់។

នៅក្នុងជំនួបរបស់ប្រមុខដឹកនាំអាស៊ាន ជាមួយតំណាងក្រុមប្រឹក្សាធុរកិច្ចអាស៊ាន (ASEAN-BAC) **សម្តេចធិបតី** បានសង្កត់ធ្ងន់លើតួនាទីសំខាន់របស់វិស័យឯកជនក្នុងដំណើរការកសាងសហគមន៍សេដ្ឋកិច្ចក្នុងបរិបទនៃភាពមិនប្រាកដប្រជារបស់សេដ្ឋកិច្ចពិភពលោក។ **សម្តេចធិបតី** បានស្នើថា ក្រុមប្រឹក្សាធុរកិច្ចអាស៊ានគួរធ្វើការពិគ្រោះយោបល់បន្ថែមជាមួយស្ថាប័នអាស៊ានពាក់ព័ន្ធ និងរៀបចំផែនការសកម្មភាពរយៈពេលច្រើនឆ្នាំមួយ ដែលស្របនឹងផែនការយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ២០២៦-២០៣០ និងចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥ ហើយក៏បានបង្ហាញការជឿជាក់ថា អាស៊ានអាចកសាងអនាគតរុងរឿងរួមគ្នាមួយប្រកបដោយចីរភាព បរិយាបន្ន នវានុវត្តន៍ និងភាពធន់៕

ថ្ងៃអង្គារ ១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២៥